# អំពីប្រវត្តិស្ត្រីក្រមុំខ្មែរ

# នៅ

# សម័យអង្គរ

*អំពីប្រវត្តិស្ត្រីក្រមុំខ្មែរ នៅម័យអង្គរ នៅ ចុងសតវត្សទី១៣ គឺគ្រឹស្តសករាជ១២៩៧ ដោយកំណត់ហេតុ របស់លោកឯកអគ្គរដ្ឋទូតចិន នាមជីវ-តាក្វាន់។*

*ពួកឪពុកម្តាយ ដែលមានកូនស្រី តែឱ្យពរកូនថា "សូមឱ្យកូនឯង ទៅអានាគតទៅ បានជាស្រីដែលអានប្តីរាប់រយរាប់ពាន់"។ កូនស្រីក្នុងគ្រួសារអ្នកមាន ចាប់ពីអាយុ ៧ ទៅ ៩ឆ្នាំ និងគ្រួសារអ្នកដែលក្រខ្សត់ មានរហូតដល់អាយុ ១១ឆ្នាំ គឺគេនិមន្តលោក ឬតាបស មកធ្វើពិធីបើកមុខ កូនស្រីដែលហៅថា ចឹនថាន់។*

*ពិធីនេះ រា ជការបានដាក់កម្រិត ឱ្យធ្វើមួយឆ្នាំម្តង នៅក្នុងខែដែលត្រូវនឹង ខែទី ៤ របស់ចិន ដោយរើសយកថ្ងៃណាមួយ ធ្វើក៏បានដែរ។ អ្នកមានកូនស្រី ដែលត្រូវធ្វើពិធីនេះ តោងជំរាបរាជការជាមុន ហើយអ្នករាជការ គេក៏បានឱ្យទៀនធំមួយដើម មកទុកជាមុន និងមានគូសគំនូសមួយជាកំណត់សញ្ញានៅនឹងទៀន ហើយប្រាប់ថា ចាំដល់ពេលយប់ ចាំធ្វើពិធីនេះ បើដុតទៀនអស់ដល់កម្រិតនោះហើយ ត្រូវចាប់ផ្តើមធ្វើពិធី ចឹនថាន់ឡើង។*

នៅមុនពេលដែលធ្វើពិធីនេះមួយខែឬកន្លះខែ ឬក៏ដប់ថ្ងៃ ឪពុកម្តាយត្រូវជ្រើសរើសយកលោកឬតាបសណាមួយ ប្រកាន់ទុកជាមុន ទោះបីនៅវត្តណាក៏ដោយ ក៏តែងតែទៅនិមន្តបានដែរ ។

លោកគ្រូអង្គណាដែលសំខាន់ៗជាងគេ តែងតែត្រូវបានពួកមន្ត្រី ឬអ្នកមានគេនិមន្តទុកអស់ហើយ រីឯអ្នកក្រ ពុំអាចជ្រើសរើសរកលោកបាន តាមចំណង់ឡើយ។ មន្ត្រីឬអ្នកមានគេបូជាលោកនូវសុរា អង្ករ កំណាត់សំពត់ ស្លាម្លូ និងគ្រឿងប្រាក់យ៉ាងច្រើន រហូតដល់ទៅ ១០០ អម្រែកផង ហើយតម្លៃនោះ មិនតិចជា ងសាច់ប្រាក់ចិន ២០០ឬ៣០០ តម្លឹងឡើយ។ អ្នកមានរបស់របរតិច ក៏គង់ធ្វើអស់របស់ ៣០-៤០ ឬ១០-២០ អម្រែកដែរ។ ដូច្នេះគ្រួសារអ្នកក្រត្រូវរង់ចាំ ដល់កូនស្រីអាយុ ១១ឆ្នាំ ទើប ចាប់ធ្វើពិធីនេះ មកពីពិបាករក របស់របរទាំងនេះឯង។

មានអ្នកខ្លះគេជួយលុយ ដល់កូនអ្នកក្រ ឱ្យធ្វើពិធីនេះ ដែលគេទុកជាការ កសាងកុសលមួយដែរ។ ក្នុងមួយឆ្នាំ លោកឬតាបសមួយអង្គ អាចទទួលនិមន្ត ធ្វើពិធីនេះ ឱ្យក្មេងស្រីបានតែមួយនាក់ទេ ហើយបើទទួលយល់ព្រម ជាមួយនឹងអ្នកណាហើយ មិនអាចទទួលនិមន្ត របស់អ្នកដទៃទៀតបានទេ។

នៅពេលយប់ដែលគេធ្វើពិធីនេះ គេមានរៀបចំគ្រឿង ស៊ីផឹកនិងភ្លេងភ្លាត់ ទ្រហឹងអឺងកង។ ក្រៅពីការជួបជុំញាតិមិត្តជិតឆ្ងាយ គេបាន សង់ធ្វើជាពេងមួយ សំរាប់ដំកល់ រូបមនុស្ស រូបសត្វដែលសូន្យអំពីដី។ អ្នកមានយសសក្តិ គេធ្វើរូបនេះដល់ទៅ ជាងដប់ រីឯអ្នកមិនសូវមានយ៉ាងហោចក៏មាន បីឬបួនដែរ។

ចំពោះអ្នកដែលទីទាល់ក្រខ្វាំងវិញ គ្មានធ្វើរូបនេះទេ គិតតែធ្វើពិធីតែម្តងទៅ លុះដល់ពេលគម្រប់៧ថ្ងៃ ទើបគេរុះរោងនោះចេញ។ នៅពេលយប់ ដែលធ្វើពិធីនោះទៀត គេយកគ្រែស្នែងទៅនិមន្តលោក ហើយបាំងក្ងស់ និងមានលេ ងភ្លេងដង្ហែ នាំយកមកផង។ គេមា នកូនតួបពីរដូចគ្រែស្នែងដែរ ដែលមានបិទបាំង អំអរទៅដោយ ព្រៃ ពណ៌ភ្លឺព្រាលៗ តួបមួយសំរាប់កូនស្រីនោះអង្គុយ រីឯតួបមួយទៀត សំរាប់លោកឬតាបសគង់សូត្រធម៌ តែខ្ញុំមិនដឹងថាលោកសូត្រអ្វីឡើយ ហើយ នៅពេលនោះ ភ្លេងក៏ប្រគុំឮគឹកកងរំពងដែរ។ ខ្ញុំឮថាពេលយប់ហ្នឹង គ្មានត្រណមអ្វីទេ គ្រាន់តែដឹងថា ដល់ពេលវេលាភ្វាម លោកឬតាបស នោះក៏ចូលទៅក្នុងបន្ទប់ ជាមួយកូនស្រីហើយលូកដៃរបស់លោកផ្ទាល់ ទៅយករបស់កូន ស្រី ទៅដាក់ក្នុងស្រា។ ខ្វះថាឪពុកម្តាយនិងញាតិមិត្ត យករបស់កូននោះ ទៅផ្តិតនិងថ្ងាស ឬមុខរៀងៗខ្លួ ន។ ខ្វះទៀតថា យកមកភ្លក់គ្រប់គ្នាហើយខ្វះថា លោកឬតាបស ក៏រួមរ័កជាមួយកូនស្រីក្នុងពេលនោះដែរ តែអ្នកខ្វះថាឥតមានការរួមរ័កទេ។ រឿងនេះ គេមិនបានឱ្យពួកចិនឃើញ ផ្ទាល់នឹងភ្នែកទេ ហេតុនេះទើបខ្ញុំមិនអាចដឹងការពិតឡើយ។

លុះដល់ពេលទៀបភ្លឺ ទើបគេដង្ហែរលោកឬតាបស ដោយគ្រែស្នែង ដែលមា នភ្លេងនិងរបាំងក្ងស់ នាំយកទៅ វិញ ហើយគេយករបស់ល្អៗ មានព្រៃពណ៌ជាដើម ទៅធ្វើជាថ្នូរដើម្បីលួសយកកូនស្រីនោះមកវិញ។ បើពុំធ្វើដូច្នោះទេ កូនស្រីនេះ មិនអាចយកទៅ ឱ្យមានប្តីដទៃទៀតបានឡើយ ពីព្រោះនៅជាកម្មសិទ្ធ របស់លោកឬតាបសនៅឡើយ។

ពេលដែលខ្ញុំបានឃើញរឿងរ៉ាវនេះ គឺនៅថ្ងៃ ៦ ខែទី៤ នៃឆ្នាំតេងអ៊ីវ ឬឆ្នាំ១២៩៧។

នៅពេលដែលមុនធ្វើពិធីនេះ កូនស្រីត្រូវនៅដេកក្នុងបន្ទប់ ជាមួយឪពុកម្តាយ លុះដល់ធ្វើពិធីនេះរួចហើយ កូនស្រីត្រូវបែកទៅដេកនៅបន្ទប់ដទៃ ហើយនាងចង់ទៅដេកកន្លែងណាក៏បាន តាមចិត្តចង់ ឥតមាននរណាតាមមើល ឬឃ្លាំចាំមើលឡើយ។

ចំពោះរឿងរៀបអាពាហ៍ពិពាហ៍វិញ ពិតមែនតែមានតម្រូវ ឱ្យជូនលុយកាក់ជាច្រើន ប៉ុន្តែគេមានអនុគ្រោះជាច្រើនដែរ។ មានអ្នកខ្លះគេអាច ដេកនៅរួមរ័កនឹងគ្នា ជាមុនរួចទៅ ហើយទើបរៀបការជាក្រោយក៏បាន។ តាមប្រពៃណីគេ មិនមាន ចាត់ទុកការណ៍នេះ ជាការគួរខ្មាសអៀន ឬជាចម្ងៃកឡើយ។

នៅយប់ដែលធ្វើពិធី "ធឹនថាន" នោះ ជួនកាលនៅតាមផ្លូវតែមួយ មានគេធ្វើពិធីនេះរហូតដល់ដប់ផ្ទះឯណោះ។ នៅតាមទីក្រុង អ្នកណាហ៊ានដើរកាត់ហ្វូងពិធី ពីមុខលោកឬតាបសទាំងនេះ ច្បាស់ជាវង្វេងផ្លូវហើយ ឬក៏ឮសូរក្អេងគឹកកង គ្មានចន្លោះពេលណាឡើយ៕